August 9, 2019

# ជប៉ុនមានកង្វល់អំពីការរឹតត្បិតសិទ្ធិសេរីភាពរបស់កម្ពុជា និងការចាប់មេបក្សប្រឆាំងដាក់គុក




លោក កឹម សុខា (ដើរមុខ) ប្រធានគណបក្សសង្គ្រោះជាតិ នាស្នាក់ការកណ្ដាលគណបក្សសង្គ្រោះជាតិ បន្ទាប់ពីប្រជុំផ្ទៃក្នុងគណបក្ស កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៦។ Photo: RFA

**ដោយ ហេង រស្មី RFA 2019-08-07**

*រដ្ឋាភិបាលជប៉ុនបានលើកឡើងពីក្ដីកង្វល់របស់ខ្លួនទាក់ទងនឹងការរឹតត្បិតសិទ្ធិសេរីភាព និងការចាប់មេបក្សប្រឆាំងដាក់គុក។*

*លោក កែវ រ៉េមី ប្រធានគណៈកម្មការសិទ្ធិមនុស្សកម្ពុជា ប្រាប់សារព័ត៌មានក្នុងស្រុកថា នៅក្នុងជំនួបជាមួយលោក ម៉ាសាតុ អូតាកា* (Masato Otaka) *អគ្គនាយករងការិយាល័យគោលនយោបាយការបរទេស និងជាឯកអគ្គរាជទូត ទទួលបន្ទុកកិច្ចការសហប្រជាជាតិ នៃក្រសួងការបរទេសជប៉ុន កាលពីថ្ងៃទី៧ សីហាថា ភាគីជប៉ុន បានលើកឡើងអំពីការរំលាយបក្សសង្គ្រោះជាតិ ការឃុំខ្លួនលោក កឹម សុខា ឃាតកម្មលោក កែម ឡី ព្រមទាំងសិទ្ធិសេរីភាពសម្ដែងមតិ និងការប្រជុំរបស់សង្គមស៊ីវិល ព្រមទាំងបញ្ហាមួយចំនួនទៀត។*

*លោកនិយាយថា លោកបានបកស្រាយប្រាប់ភាគីជប៉ុនពីបញ្ហាទាំងនេះថា ទាំងអស់នេះ គឺជាការអនុវត្តច្បាប់របស់តុលា*

ការកម្ពុជា។

លោក កែវ រ៉េមី អះអាងថា ភាគីជប៉ុនបានទទួលយកអ្វីដែលលោកបានបកស្រាយ។

អ្នកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា យល់ឃើញថា ចំណាប់អារម្មណ៍របស់ជប៉ុនលើបញ្ហាសិទ្ធិមនុស្សនៅកម្ពុជាគួរឲ្យស្វាគមន៍ ប៉ុន្តែជំនួបនេះ គួរតែធ្វើឡើងដោយមានតម្លាភាពដោយមានការចូលរួមពីសហគមន៍ការពារសិទ្ធិមនុស្ស និងធ្វើឡើងជាទៀងទាត់។ លោកស្រីសង្ឃឹមដែរថា ជប៉ុនដែលជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងជាអ្នកសម្របសម្រួលសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិកាលពីឆ្នាំ ២០១៨ នឹងចូលរួមបន្ថែមទៀតដល់ការកសាងសន្តិភាពនៅកម្ពុជា៕